# ក្រសួងអប់រំប្រចាំក្រុងហ្វីឡាដែលហ្វ្យ៉ា

# របៀបដាក់ពាក្យសុំចូលរៀននៅសាលាមធ្យមសិក្សា

## *ល្បិចដ៏មានប្រយោជន៍ផ្សេងៗសំរាប់មាតាបិតា*

<u>មាតាបិតា/អាណាព្យាបាលរបស់សិស្សដែលរៀននៅថ្នាក់ទី៦ ទី៧ និង ទី៨</u>

- និយាយជាមួយកូនរបស់លោកអ្នកអំពី **ការចាប់អារម្មណ៍**និងប៉ិនប្រសប់របស់ពួកគេ។ ធ្វើគំរោងការជុំគ្នាសំរាប់អនាគតរបស់កូនលោកអ្នក។ ទាក់ទងទៅអ្នកអោយឱវាទនៅសាលាកូនរបស់លោកអ្នក ដើម្បីរកមើលថាតើត្រូវមានការសិក្សា និង/ឬ ការហ្វឹកហ្វឺនអ្វីសំរាប់ការងារដែលពួកគេចូលចិត្តធ្វើ។

- **សង្កេតមើលការទៅរៀន**របស់កូនលោកអ្នក **ពិន្ទុ** និង**អត្តចរិត**របស់កូនលោកអ្នក។ ទាំងនេះគឺជាលក្ខណៈវិនិច្ឆ័យដ៏សំខាន់សំរាប់របៀបដាក់ពាក្យសុំចុះឈ្មោះចូលរៀនពិសេស និងការចុះឈ្មោះចូលរៀនសាលាមធ្យមសិក្សាប្រចាំក្រុង។

- ពេលណាកូនរបស់លោកអ្នកមិនបានទៅរៀន សូមផ្ញើសំបុត្រជំរាបពី**ការមិនបានទៅរៀន**ទៅគ្រូបង្រៀន ដែលពន្យល់ពី**ហេតុផលចំពោះការមិនបានទៅរៀន**នេះ ដើម្បីអោយមានការកត់សំគាល់ថាការមិនបានទៅរៀននេះត្រូវ**លើកលែងអោយ**។ សំណុំរឿងដែលបង្ហាញពីការទៅរៀនអោយបានទៀងទាត់របស់កូនលោកអ្នកនឹងជាការសំខាន់នៅពេលដាក់ពាក្យសុំចូលរៀននៅសាលាមធ្យមសិក្សា មហាវិទ្យាល័យ និង សាលាវិជ្ជាជីវៈដែលមានគេចូលចិត្តច្រើន។

- បើលោកអ្នកមានការបារម្ភអំពី**អត្តចរិត**របស់កូនលោកអ្នកនៅសាលា សូមទាក់ទងមកសាលាដើម្បីពិភាក្សារកការគាំទ្រ។

- បើលោកអ្នកមានការបារម្ភអំពី**ពិន្ទុ**ដែលកូនរបស់លោកអ្នកបាន សូមទាក់ទងមកសាលាដើម្បីពិភាក្សារកការគាំទ្រនិងសេវាការដែលកូនរបស់លោកអ្នកកំពុងទទួលពីកម្មវិធីសំខាន់ៗ។ សិស្សណាដែលមានភាពពិការ គួរតែអោយពិន្ទុទៅតាមខដែលមានចែងនៅលើការស្ទង់មើលរបស់គេម្នាក់ៗ។

- បើលោកអ្នកមានការបារម្ភអំពី**ពិន្ទុលើការធ្វើតែស៏ដែលគេយកតាមទូទៅ** សូមសួរសំណួរអំពីនាទីរបស់ពិន្ទុរបស់តែស៏ក្នុងការដាក់ពាក្យសុំចូលរៀននៅសាលាមធ្យមសិក្សា។ នេះគឺជាការពិភាក្សាមួយផ្នែកដើម្បីអោយដឹងថាតើកូនរបស់លោកអ្នកគួរធ្វើតែស៏ Terra Nova ចុះមួយក៏រឺតប្អូអត់។

- លើកទឹកចិត្តកូនរបស់លោកអ្នកអោយចូលរួមក្នុងកម្មវិធីដែលមាននៅតាមសហគម និងកម្មវិធីក្រោយពេលចេញពីរៀន ដែលបង្កើតឡើងដើម្បី**បណ្ដុះបណ្ដាលនៅការចូលចិត្តនិងការប៉ិនប្រសប់**របស់កូនលោកអ្នក។ ដើម្បីពត៏មាន សូមទាក់ទងមកអ្នកអោយឱវាទនៅសាលា។ ហើយក៏សាកសួរអំពីអ្វីៗដែលលោកអ្នកអាចធ្វើនៅផ្ទះដើម្បីជួយកូនរបស់លោកអ្នកបណ្ដុះបណ្ដាលនូវអ្វីៗទាំងនេះ។

ពិនិត្យមើល**បញ្ជីឈ្មោះសាលាមធ្យមសិក្សា**។ និយាយអំពីកម្មវិធីដែលកូនរបស់លោកអ្នកចាប់អារមណ៍។ សរសេរឈ្មោះសាលាទាំងអស់ដែលលោកអ្នកចង់ទៅមើលនៅឯទីតាំងពិពណ៌សាលាមធ្យមសិក្សា។ បញ្ជីឈ្មោះសាលាមាននៅតាមសាលារបស់កូនលោកអ្នក និងតាមកុំព្យូទ័រ។
http://www.phila.k12.pa.us/offices/sem/main.html

- សូមមកចូលរួមនៅពិធី**តាំងពិពណ៌**។ សូមសាកសួរតាមរានសាលាមធ្យមសិក្សាណាដែលផ្ដល់កម្មវិធីដែលកូនលោកអ្នកចាប់អារម្មណ៍។ **សួរសំណួរ**ដែលទាក់ទងនឹងកម្មវិធីដែលគេផ្ដល់អោយ និងអំពីការតំរូវសំរាប់ការដាក់ពាក្យសុំ។ បើមានការតំរូវពិសេសសំរាប់ ការធ្វើសាកមើល ធ្វើសមាសន៏ ការសរសេរសាកល្បង ឬ portfolios សូមទាក់ទងមកអ្នកអោយឱវាទនៅសាលា ដើមីការគាំទ្រនៅសាលា។ សាកសួរថាតើលោកអ្នកអាចជួយដោយរបៀបណានៅផ្ទះ។

- បើចាំបាច់ ស្នើសុំប្រជុំ IEP ដើម្បីនិយាយអំពីការរីកចំរើននៃការសិក្សានិងអត្តចរិតរបស់កូនលោកអ្នក អំពីកម្មវិធីនៅសាលាមធ្យមសិក្សានិងការជ្រើសរើស ហើយបើការតំរូវនៃការចុះឈ្មោះអាចមានការលើកលែងដល់ការតំរូវទាំងនេះចំពោះកូនរបស់លោកអ្នក **ក្រុម IEP** និងសំរេចថាតើកូនរបស់លោកអ្នកអាចចូលរួមក្នុងកម្មវិធីដែលពួកគេចង់ដាក់ពាក្យសុំ យោងទៅតាមសេវាការនិងការគាំទ្រដែលមានបញ្ជាក់ក្នុង IEP របស់ពួកគេ។